Institut Pasteur du Cambodge

*រៀបរៀងដោយ វេជ្ជ.ហេង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំ (Seasonal Flu Vaccine)

## ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំ?

ជំងឺគ្រុនផ្តាសាយធំបណ្តាលមកពីមេរោគគ្រុនផ្តាសាយធំ (Influenza virus) ហើយមេរោគនេះឆ្លងរាលដាលតាមការក្អក កណ្តាស់ និងការប៉ះពាល់គ្នាជិតស្និទ្ធ។ មនុស្សគ្រប់រូបអាចកើតជំងឺផ្តាសាយធំនេះ តែកុមារប្រឈមនឹងការឆ្លងជំងឺនេះខ្ពស់ជាងគេ។ រោគសញ្ញាអាចលេចឡើងភ្លាមៗ ក្រោយការឆ្លង ហើយវាអាចស្ថិតនៅ៣ទៅ៤ថ្ងៃ។ រោគសញ្ញានៃជំងឺគ្រុនផ្តាសាយរួមមាន៖

- គ្រុនក្តៅ ញាក់
- ឈឺបំពង់ក ឈឺសាច់ដុំ ឈឺក្បាល ល្ហិតល្ហៃ
- ក្អក ហៀរសំបោរ ឬតឹងច្រមុះ

ជំងឺគ្រុនផ្តាសាយធំនេះអាចមានអការៈធ្ងន់ធ្ងរលើមនុស្សមួយចំនួន ជាពិសេសកុមារតូចៗ មនុស្សចាស់ដែលមានអាយុលើសពី ៦៥ឆ្នាំ ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺរ៉ាំរ៉ៃ និងអ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។ មេរោគគ្រុនផ្តាសាយធំនេះក៏អាចបណ្តាលអោយមានជំងឺរលាកសួត និងអាចធ្វើអោយជំងឺប្រចាំកាយរបស់អ្នកជំងឺវិវត្តិន៍ទៅជាធ្ងន់ធ្ងរផងដែរ។

វ៉ាក់សាំងបង្ការជំងឺផ្តាសាយធំអាចការពារអ្នកពីការឆ្លងជំងឺនេះ ហើយក៏អាចជួយការពារមិនអោយជំងឺនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានផងដែរ។

## ២- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការជំងឺផ្តាសាយធំ?

ការចាក់វ៉ាក់សាំងបង្ការជំងឺផ្តាសាយធំត្រូវបានគេណែនាំអោយធ្វើរៀងរាល់ ១ឆ្នាំ ម្តង។ ដោយឡែកកុមារ ដែលមានអាយុចាប់ពី ៦ខែ-៨ឆ្នាំ គួរចាក់វ៉ាក់សាំងបង្ការនេះចំនួន២ដង ក្នុងឆ្នាំដំបូង ដែលពួកគេទើបចាប់ផ្តើមទទួលវ៉ាក់សាំងនេះ។

មេរោគផ្តាសាយធំ (Influenza virus) អាចបំលែងខ្លួនដោយប្តូរទំរង់ថ្មីៗជានិច្ច ដោយហេតុនេះហើយជារៀងរាល់ឆ្នាំ វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំត្រូវបានគេផលិតឡើង ដោយការដាក់បញ្ចូលនូវក្រុមមេរោគគ្រុនផ្តាសាយធំចំនួន ៣-៤ទំរង់ ដែលគេរំពឹងថានឹងរាតត្បាតខ្លាំង នៅក្នុងឆ្នាំនោះ។

វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំនេះមិនអាចការពារការកើតជំងឺគ្រុនផ្តាសាយធំបានទាំងស្រុងនោះទេ ប៉ុន្តែវាជាវិធីសាស្ត្រដ៏ល្អបំផុត ដើម្បីបង្ការជំងឺគ្រុនផ្តាសាយធំនេះ។ វាទាមទារពេលវេលាប្រហែល ២សប្តាហ៍ ក្រោយពេលទទួលចាក់វ៉ាក់សាំងបង្ការ ដើម្បីអោយវ៉ាក់សាំងនេះមានប្រសិទ្ធភាពពេញលេញ។ វ៉ាក់សាំងនេះ អាចមានប្រសិទ្ធភាពជាច្រើនខែ រឺរហូតដល់មួយឆ្នាំ។

មានជំងឺមួយចំនួនអាចមានរោគសញ្ញាប្រហាក់ប្រហែលនឹងជំងឺផ្តាសាយធំ ប៉ុន្តែវាមិនមែនបង្កឡើងដោយមេរោគគ្រុនផ្តាសាយធំឡើយ។ ថ្នាំបង្ការជំងឺគ្រុនផ្តាសាយធំមិនអាចការពារការកើតជំងឺទាំងអស់នោះបានឡើយ។

ដើម្បីរក្សាគុណភាពរបស់វ៉ាក់សាំង សារធាតុបារត (Thimerosal) ក្នុងបរិមាណតិចតួចត្រូវបានគេប្រើប្រាស់ នៅក្នុងវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំមួយចំនួន។ តាមការសិក្សាជាច្រើនបានបង្ហាញថា បរិមាណបារតតិចតួច នៅក្នុងវ៉ាក់សាំងនេះ មិនបណ្តាលអោយមានគ្រោះថ្នាក់ឡើយ ក៏ប៉ុន្តែ វ៉ាក់សាំងដែលគ្មានជាតិបារតនេះក៏អាចរកបានដែរ។

## ៣- តើអ្នកណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមានក្នុងវ៉ាក់សាំងនេះ ជាពិសេសគឺអ្នកដែលមានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយស៊ុតមាន់។
- អ្នកដែលធ្លាប់មានចង្កោមរោគសញ្ញាបញ្ហាប្រព័ន្ធសរសៃប្រសាទធ្ងន់ធ្ងរ (Guillain-Barre Syndrome)។
- អ្នកដែលមានអារម្មណ៍ថាមិនស្រួលខ្លួន។

## ៤- ផលវិបាកដែលអាចកើតមានក្រោយពេលចាក់វ៉ាក់សាំងនេះ

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលថ្នាំវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល ល្ហិតល្ហៃ
- ក្អក រមាស់ភ្នែក រឺ ភ្នែកឡើងក្រហម

ការវិងវិលមុខមួយស្របក់ និងសញ្ញាជាប់ទាក់ទងអាចកើតមានឡើង បន្ទាប់ពីការព្យាបាលអ្វីមួយ រួមទាំងការចាក់វ៉ាក់សាំងផងដែរ។ ការអង្គុយចុះ ឬ តម្រេតខ្លួន ប្រហែល ១៥នាទី បន្ទាប់ពីចាក់ថ្នាំរួច អាចជួយការពារកុំអោយមានភាពធីងធោង និងអាចបញ្ចៀសការដួល ដោយសារវិងវិលមុខ។

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**